ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០១៧ សប្រក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃការរៀបចំពិធីបើក «ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥» អមដោយការសម្តែងសិល្បៈពិសេស «សម្រស់កម្ពុជា-ជាំងស៊ូ»
រាជធានីភ្នំពេញ, ថ្ងៃទី២៣-២៥ ខែឧសភា ឆ្នាំ២០២៥

ដោយទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងទេសចរណ៍ សហការជាមួយស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលប្រជាជនខេត្តជាំងស៊ូ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បានរៀបចំពិធីបើក «**ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥**» អមដោយការសម្តែងសិល្បៈពិសេស «**សម្រស់កម្ពុជា-ជាំងស៊ូ**» ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ ដោយទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

**ពិធីបើក «ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥»៖**

នារាត្រីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥ ពិធីបើក «**ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥**» ត្រូវបានរៀបចំឡើងនៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **ឯកឧត្តម ហ៊្សី យុនលីន (Xu Kunlin) អភិបាលខេត្តជាំងស៊ូ នៃសាធារណរដ្ឋប្រជាមានិតចិន** ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តម វ៉ាង វិនពីន (Wang Wenbin) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា** និង **ឯកឧត្តម ឯក សំអុល ប្រធានសមាគមមិត្តភាពកម្ពុជា-ចិន** ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង ស្ថាប័ន តំណាងអង្គទូតនៃប្រទេសជាមិត្ត និងភ្ញៀវជាតិ-អន្តរជាតិ សរុបប្រមាណជិត ១០០០នាក់ ព្រមទាំងបណ្តាញសារព័ត៌មានទាំងកម្ពុជា និងចិនជាច្រើនផងដែរ។ ការប្រារព្ធពិធីបើកជាផ្លូវការ «ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥» នេះ គឺជាលទ្ធផលជាប្រវត្តិសាស្រ្តនៃដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម ស៊ី ជីនពីង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន** មកកាន់ព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៧-១៨ ខែមេសា ឆ្នាំ២០២៥ ដោយ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និង **ឯកឧត្តមប្រធានាធិបតី** បានឯកភាពកំណត់យកឆ្នាំ២០២៥ ជា «ឆ្នាំទេសចរណ៍ កម្ពុជា-ចិន» បន្តពីឆ្នាំ២០២៤ ដែលត្រូវបានកំណត់ជា «ឆ្នាំនៃការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន កម្ពុជា-ចិន»។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ ឯកឧត្តមអភិបាលខេត្ត ឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តមអគ្គរដ្ឋទូត** បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ដែលបានពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរស្របតាមស្មារតី «**មិត្តដែកថែប និងសហគមន៍វាសនារួមកម្ពុជា-ចិន ប្រកបដោយភាពស៊ីជម្រៅ និងភាពជាក់ស្តែងក្នុងយុគសម័យថ្មី**» ក៏ដូចជា**កិច្ចសហប្រតិបត្តិការត្បូងពេជ្រ រវាងកម្ពុជា-ចិន** ជាពិសេស ការដាក់ចេញនូវ "**ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន**" ដែលប្រទេសទាំងពីរបានទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា

ក្នុងឆ្នាំ២០២៤កន្លងមក ជាពិសេសវិស័យទេសចរណ៍ ដោយកាលពីឆ្នាំ២០២៤កន្លងទៅ កម្ពុជាទទួលបានទេសចរចិនប្រមាណ **៨៥ម៉ឺននាក់** កើនឡើង **៥៥%** ធៀបនឹងឆ្នាំ២០២៣។

ពិធីបើកជាផ្លូវការ **"ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥"** បានប្រារព្ធឡើងយ៉ាងអធិកអធម ដោយមានការសម្តែងផ្ទាំងទស្សនីយភាព ការសម្តែងសិល្បៈ របាំប្រពៃណី ការសម្តែងសៀកកាយសម្ព័ន្ធរួមគ្នា សិល្បៈល្ខោនបាសាក់ និងហ៊ី ជំនួបរវាងហនុមាន និងស៊ុនអ៊ូខុង ការប្រគំតន្ត្រី និងសម្តែងរួមគ្នា ដោយសិល្បករ សិល្បការិនីនៃប្រទេសទាំងពីររាប់រយនាក់ ភ្ជាប់ដោយការចាក់បញ្ចាំងវីដេអូផ្សព្វផ្សាយគោលដៅទេសចរណ៍កម្ពុជា និងខេត្តជាំងស៊ូ ដែលបានបង្ហាញយ៉ាងច្បាស់ពីសក្តានុពលទេសចរណ៍ប្រកបដោយភាពទាក់ទាញនៃប្រទេសទាំងពីរ។ នាព្រឹត្តិការណ៍ពិធីបើកដ៏អធិកអធិមនេះ ក៏មានការរៀបចំស្តង់ពិព័រណ៍ទេសចរណ៍ និងវប្បធម៌ កម្ពុជា-ចិន ដោយមានការដាក់តាំងបង្ហាញនូវបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា និងចិន ជាពិសេសសម្បត្តិវប្បធម៌ដែលត្រូវបានចុះបញ្ជីបេតិកភណ្ឌពិភពលោកយូណេស្កូ ដែលទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីគណៈអធិបតី និងអ្នកទស្សនាទាំងភាគីចិន និងកម្ពុជា។

បន្ថែមលើនេះ ដើម្បីអបអរសាទរការចាប់ផ្តើមដំណើរការយុទ្ធនាការ **«ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥»** ក្រសួងទេសចរណ៍ ដោយសហការជាមួយស្ថានទូតចិនប្រចាំកម្ពុជា និងរដ្ឋបាលប្រជាជនខេត្តជាំងស៊ូ ក៏បានបន្តរៀបចំទស្សនីយភាពសម្តែងសិល្បៈរួមគ្នា កម្ពុជា-ចិន សម្រាប់មហាជនទស្សនា នាល្ងាចថ្ងៃទី២៤ និង២៥ ខែឧសភា ឆ្នាំ២០២៥ នៅបរិវេណសួនច្បារតេជោមាសតេជោយ៉ត ដោយទទួលបានការសាទរយ៉ាងកុះករពីភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលដើរកម្សាន្តតាមបណ្តោយផ្លូវថ្មើរជើងមាត់ទន្លេចតុមុខ។ នាឱកាសនៃការសម្តែងសិល្បៈមហាជននេះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង ឯកឧត្តមឯកអគ្គរដ្ឋទូតចិន ក៏បានអញ្ជើញទស្សនាទិដ្ឋភាពជាក់ស្តែងនៃផ្លូវថ្មើរជើង (Walk Street) នាពេលរាត្រី ដើម្បីបង្ហាញ និងផ្សព្វផ្សាយអំពីភាពសម្បូរបែបនៃទេសចរណ៍កម្ពុជា និងបង្ហាញពីកត្តាសុខសន្តិភាព ស្ថានភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សង្គមពិតជាក់ស្តែងនៅកម្ពុជា ជាពិសេសអំពីទេសចរដែលមកទស្សនាកម្សាន្ត ប្រកបដោយសុខសុវត្ថិភាព ជូនដល់ពិភពលោក ជាពិសេសភ្ញៀវទេសចរចិន។

**<u>ជំនួបពិភាក្សាការងារ និងការចុះអនុស្សរណៈនៃការយោគយល់គ្នា</u>**

ឆ្លៀតក្នុងឱកាសដែលគណៈប្រតិភូសាធារណរដ្ឋប្រជាមានិតចិន អញ្ជើញចូលរួមពិធីបើក **«ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥»** នារសៀលថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥ **ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍** និង **ឯកឧត្តម ហ៊្សី យុនលីន (Xu Kunlin) អភិបាលខេត្តជាំងស៊ូ** ក៏បានជួបពិភាក្សាការងារលើកិច្ចសហប្រតិបត្តិការទេសចរណ៍រវាងខេត្តជាំងស៊ូ និងកម្ពុជា ជាពិសេសការជំរុញលំហូរទេសចរខេត្តជាំងស៊ូ ឱ្យមកទស្សនាកម្ពុជាឱ្យបានកាន់តែច្រើនឡើងថែមទៀត។

នាឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍** និង **ឯកឧត្តមអភិបាលខេត្តជាំងស៊ូ** ក៏បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ធ្វើជាសក្ខីភាពនៃការចុះអនុស្សរណៈនៃការយោគយល់គ្នាចំនួន **៦** រួមមាន៖

១. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការទេសចរណ៍រវាងមន្ទីរទេសចរណ៍ខេត្តសៀមរាប និងមន្ទីរវប្បធម៌ និងទេសចរណ៍ខេត្តជាំងស៊ូ។

២. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការទេសចរណ៍រវាងមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ និងមន្ទីរវប្បធម៌ និងទេសចរណ៍ខេត្តជាំងស៊ូ។

៣. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការមិត្តភាព និងការផ្លាស់ប្តូរការសិក្សា រវាងវិទ្យាស្ថានជាតិទេសចរណ៍កម្ពុជា និងវិទ្យាស្ថានទេសចណ៍ និងបដិសណ្ឋារកិច្ចណានជីង។

៤. អនុស្សរណៈនៃការយោគយល់គ្នា រវាងក្រុមហ៊ុន CaHeng International Cultural Tourism Investment Co., Ltd និងក្រុមហ៊ុន Jiangsu Performing Arts Group Co., Ltd។

៥. អនុស្សរណៈនៃការយោគយល់គ្នា រវាងសមាគមទេសចរណ៍កម្ពុជា និងក្រុមហ៊ុន Tuniu Corp។

៦. អនុស្សរណៈនៃការយោគយល់គ្នា រវាងសមាគមទេសចរណ៍កម្ពុជា និងក្រុមហ៊ុន Nanjing Niushou Mountain Cultural Tourism Group Co., Ltd ។

ស្របជាមួយការរៀបចំព្រឹត្តិការណ៍ពិធីបើក **«ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥»** នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ ក្រសួងទេសចរណ៍ បាននិងគ្រោងទទួលបដិសណ្ឋារកិច្ចភ្ញៀវទេសចរចិន ចំនួនប្រមាណជាង ១០០០នាក់ ដំបូង និងជាដំណាក់កាលបន្តបន្ទាប់ ដែលកញ្ចប់ទស្សនកិច្ចទេសចរណ៍មកកាន់កម្ពុជាដែលមានទំហំដ៏ធំនេះ គឺជាលទ្ធផលផ្លែផ្កានៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ និងការរៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍រវាងក្រសួងទេសចរណ៍កម្ពុជា ជាមួយក្រុមហ៊ុន China Tourism Group ( CTG ) ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ កន្លងទៅផងដែរ។

ជារួម ពិធីបើកជាផ្លូវការ **«ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥»** បានប្រព្រឹត្តទៅប្រកបដោយភាពអធិកអធម ជោគជ័យ និងផ្លែផ្កាគួរជាទីមោទនៈសម្រាប់វិស័យទេសចរណ៍កម្ពុជា តាមរយៈការផ្សព្វផ្សាយទេសចរណ៍ ការភ្ជាប់ទំនាក់ទំនងនិងបណ្តាញធុរកិច្ច ការចុះអនុស្សរណៈនៃការយោគយល់គ្នា ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍រួមគ្នា និងកម្មវិធីទាក់ទាញទេសចរក្នុងខេត្តជាំងស៊ូ ក៏ដូចជាប្រទេសចិន ស្របតាមស្មារតីនៃ **«ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥»** ដែលជាការជំរុញកិច្ចសហការស៊ីជម្រៅជាមួយគ្រប់ភាគីពាក់ព័ន្ធ ស្របតាមគោលការណ៍កិច្ចសហប្រតិបត្តិការទេសចរណ៍ដែលទាមទារការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ថ្ងៃច័ន្ទ ១៥រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥